# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ អញ្ជើញជាអធិបតី ក្នុងកិច្ចប្រជុំត្រួតពិនិត្យលទ្ធផលការងារ និងលើកទិសដៅអនុវត្តបន្ត របស់ក្រុមការងារថ្នាក់ជាតិខេត្តចុះមូលដ្ឋានក្រុង-ស្រុក ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តកំពត



កិច្ចប្រជុំត្រួតពិនិត្យលទ្ធផលការងារ និងលើកទិសដៅអនុវត្តបន្ត របស់ក្រុមការងារថ្នាក់ជាតិ ខេត្តចុះមូលដ្ឋានក្រុង-ស្រុក ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវបានប្រារព្ធធ្វើឡើង នៅព្រឹកថ្ងៃទី០៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ ក្រោមអធិបតីភាពឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋានខេត្តកំពត ដើម្បី ត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា នៅសាលប្រជុំសាលាខេត្តកំពត ។



ឯកឧត្តម **ខូយ ឃុនហ៊ួរ** អភិបាល នៃគណៈអភិបាលខេត្តកំពត និងជាអនុប្រធានអចិន្ត្រៃយ៍ ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពត បានអញ្ជើញថ្លែងសន្ទរកថាស្វាគមន៍ និងធ្វើរបាយការណ៍ ដោយបានលើកឡើងពីភាពរីកចម្រើន និងការអភិវឌ្ឍន៍ នូវសមិទ្ធផលថ្មីៗជាច្រើន ដែលធ្វើឱ្យប្រជាពលរដ្ឋមានការសាទររីករាយជាខ្លាំង ។ ទាក់ទងនិងលទ្ធផលរបស់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពត ក្រោមការដឹកនាំរបស់ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានសម្រេចនូវ

សមិទ្ធិផលផ្លែផ្កាជាវិជ្ជមាន ។ ក្នុងនោះ ក្រុមការងារថ្នាក់ ក្រុង ស្រុក បានចុះធ្វើវេទិកានៅតាមឃុំ សង្កាត់ ជាប្រចាំ ដោយសម្រេចបាននូវលទ្ធផល រួមមានៈតាមទិន្នន័យចាស់ គិតត្រឹម ថ្ងៃកិច្ចប្រជុំបូកសរុបលទ្ធផល និងលើកទិសដៅអភិវឌ្ឍន៍បន្ត នាថ្ងៃទី ២៦ ខែតុលា ឆ្នាម២០១៤ ចំនួនវេទិការ ចំនួន៩២លើក លើ៩៣ឃុំសង្កាត់ ដោយមានការចូលរួមពីក្រុមការងារ ប្រជាជន ព្រះសង្ឃ សរុប ១៧.២១២នាក់ ស្ត្រី ៥.៧៣៣ នាក់ និងបញ្ហាសំណូមពរ ចំនួន៩០៩ ។ ចំពោះទិន្នន័យថ្មីបានចុះធ្វើវេទិការចំនួន៣១ ឃុំ និង១សង្កាត់ ដោយមានការចូលរួម ពីប្រជាពលរដ្ឋ ចំនួន៣.៣៥៥ នាក់ស្ត្រី ១.៦៦៦ នាក់ និងមានបញ្ហាសំណូមពរចំនួន២១៤ ។ រាល់បញ្ហាសំណូមពរ ដែលបានលើកឡើងគ្រប់វេទិកាភាគច្រើន ជាតម្រូវការបន្ទាន់ និងចំណាយថវិកាច្រើន ដូចជា សុំផ្លូវ សាលារៀន មណ្ឌលសុខភាព ប្រឡាយ ទំនប់ស្ទាក់ទឹក ស្រះ អណ្តូងស្នប់ ។ល។ រីឯបញ្ហាសំណូមពរមួយចំនួនទៀត គឺអាជ្ញាធរមានលទ្ធភាពក្នុងការដោះស្រាយបាន ចាប់ពីថ្នាក់ឃុំ-សង្កាត់មកដល់ថ្នាក់ខេត្ត ដែលមានបញ្ហាសំណូមពរមួយចំនួនតូចតែប៉ុណ្ណោះ ដែលត្រូវស្នើសុំគោលការណ៍ទៅថ្នាក់ជាតិ ដូចជាៈការស្នើសុំសិទ្ធិកម្មសិទ្ធិលើដីរបស់រដ្ឋ ការស្នើសុំរបស់ប្រជាការពារឱ្យមានឯកសណ្ឋានច្បាស់លាស់ ស្នើសុំបញ្ចុះតម្លៃភ្លើង ចំនួនមន្ត្រីប៉ុស្តិ៍មិនគ្រប់គ្រាន់ ការស្នើសុំដីសម្បទានសង្គមកិច្ច ស្នើសុំក្រុមហ៊ុនមកវិនិយោគ និងការសុំបញ្ចុះតម្លៃសេវាសាធារណៈជាដើម ។ ទោះយ៉ាងណា ឯកឧត្តម អភិបាល ខេត្តក៏បានលើកបញ្ហាប្រឈមមួយជាសំខាន់ គឺ-ការចូលរួមរបស់ប្រជាពលរដ្ឋមានការថយចុះ ដោយសារការធ្វើវេទិកាតរញឹកញាប់ ដូចជាៈវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ខេត្ត និងក្រុង ស្រុក វេទិកាសាធារណៈភូមិឃុំ មានសុវត្ថិភាព វេទិកាសាធារណៈរបស់ក្រុមការងារថ្នាក់ជាតិ និងវេទិការបស់សង្គមស៊ីវិល ។ល។ ជាមួយគ្នានេះ ប្រជាពលរដ្ឋក៏មានការរវល់ជាមួយការងារប្រមូលផល និងរបរចិញ្ចឹមជីវិតផងដែរ ។ បញ្ហានេះ ឯកឧត្តម អភិបាលខេត្ត ក៏បានស្នើសុំការណែនាំពីឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ផងដែរ ។

បន្ទាប់មកអង្គពិធី បានតាមដានស្តាប់របាយការណ៍ជាបន្តបន្ទាប់ពីឯកឧត្តម លោកជំទាវ ប្រធាន និង តំណាងក្រុមការងារថ្នាក់ក្រុង ស្រុក ស្តីពីរបាយការណ៍លទ្ធផលការងារចុះធ្វើវេទិកាសាធារណៈតាមបណ្តាក្រុង ស្រុក ទាំង ០៨ ។






មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរខេត្តលើការងារអភិវឌ្ឍន៍ ដែលធ្វើឱ្យខេត្តមានការប្រែមុខមាត់ថ្មីយ៉ាងឆាប់រហ័ស ។ ទាក់ទងនិងក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពត ឯកឧត្តម ទេសរដ្ឋមន្ត្រី បានថ្លែងការកោតសរសើរ ចំពោះសកម្មភាពការងារដ៏សកម្ម ក្នុងការចុះធ្វើវេទិកាសាធារណៈតាមឃុំ សង្កាត់ ដើម្បីទទួលយកសំណូមពរ និងបញ្ហាប្រឈមនានាមកធ្វើការដោះស្រាយតាមលទ្ធភាពជាក់ស្តែង ។ ទាក់ទងនិងបញ្ហាដែលថាៈមានការចូលរួមពីប្រជាពលរដ្ឋមូលដ្ឋានមានការថយចុះ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានពន្យល់ថាៈវាជាការធម្មតាទេ ពីព្រោះប្រជាពលរដ្ឋក៏មានការមមាញឹកក្នុងការងារកសិកម្ម និងរបរចិញ្ចឹមជីវិតរបស់ពួកគាត់ ។ ក្នុងនោះ ការចុះធ្វើវេទិកាញឹកញាប់ពេក រួមជាមួយវេទិកាជាច្រើនដ៏ទៃទៀតក៏ជាបញ្ហាផងដែរ។ បញ្ហានេះ ឯកឧត្តម បានផ្តល់យោបល់ថាៈ នៅស្រុក ឃុំ ណា ដែលមានវេទិកាសាធារណៈ បានធ្វើរួចហើយ ដូចជាៈវេទិកាពិគ្រោះយោបល់របស់ខេត្ត និងក្រុង ស្រុក ជាដើម គឺយើងយករបាយការណ៍នៃវេទិកាទាំងនោះមកពិនិត្យ និងពិភាក្សាដោះស្រាយតាមលទ្ធភាពជាក់ស្តែង ដោយមិនចាំបាច់ធ្វើវេទិកាថ្នាក់ជាតិនេះ នៅទីនោះទៀតទេ ។

ស្ថិតក្នុងឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក៏បានចែកជូននូវតារាងបែងចែកបញ្ហា ដែលប្រជាពលរដ្ឋបានលើកឡើង ដោយចែកបញ្ហាដាច់ដោយឡែកពីគ្នា ដូចជាៈបញ្ហាសហគមន៍នេសាទ-បញ្ហាព្រៃឈើ-បញ្ហាសណ្តាប់ធ្នាប់សាធារណៈ-បញ្ហាសាសនា-បញ្ហាទំនាស់ដីធ្លី-បញ្ហាហេដ្ឋារចនាសម្ព័ន្ធ ជាដើម ។ ការបែងចែកតារាងនេះយើងនឹងអាចដឹងថា តើបញ្ហាអ្វីខ្លះ?ដែលយើងបានដោះស្រាយហើយជូនដល់ប្រជាពលរដ្ឋ-បញ្ហាកំពុងដំណើរការ-បញ្ហាត្រូវដាក់បញ្ជូនទៅថ្នាក់ជាតិ សម្រេច ។ល។ ជាមួយគ្នានេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ក៏បានបង្ហាញជំហរមួយចង់បង្កើតក្រុមការងារថ្មីទទួលបន្ទុកតាមវិស័យនីមួយៈ ដូចជាៈវិស័យជលផល-វិស័យព្រៃឈើ-វិស័យដីធ្លី វិស័យសាសនា វិស័យហេដ្ឋារចនាសម្ព័ន្ធ និងវិស័យដ៏ទៃៗទៀត ដែលជាកង្វល់របស់ប្រជាពលរដ្ឋដែលបានលើកឡើង ដើម្បីងាយស្រួលកំណត់បញ្ហា

និងធ្វើការដោះស្រាយ ។ ឧទាហរណ៍ថាៈការរៀបចំវេទិការសាធារណៈថ្ងៃនេះ គឺយើងលើករបៀបវីរៈ តែមួយរឺ ពីរ ប៉ុណ្ណោះ ដូចជាៈទាក់ទង ប្រជានេសាទ និងបញ្ហាដីធ្លីជាដើម ។





ដើម្បីឱ្យក្រុមការងារទាំងអស់ មានការត្រៀមខ្លួនជាមុន ទាំងមធ្យោបាយ ពេលវេលា និងលទ្ធភាពផ្សេងៗ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានកំណត់កាលបរិច្ឆេទនៃការរៀបចំពិធីបូកសរុបការងារ និងលើកទិសដៅបន្ត របស់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពត រយៈពេល០២ ខែម្តង ដោយកំណត់កាលបរិច្ឆេទច្បាស់លាស់ជាបន្តបន្ទាប់ ដូចតទៅៈ-កំណត់ថ្ងៃ ទី ០៩ ខែ មេសា ឆ្នាំ២០១៥ ៈបូកសរុបលទ្ធផលការងារ ខែ កុម្ភៈ និងមីនា-ថ្ងៃទី១១ ខែមិថុនា

ឆ្នាំ២០១៥:បូកសរុបលទ្ធផលការងារ ខែ មេសា និងឧសភា-ថ្ងៃទី១៣ ខែ សីហាឆ្នាំ២០១៥:បូកសរុបលទ្ធផលការងារ ខែមិថុនា និងកក្កដា-ថ្ងៃទី១៥ ខែ តុលា ឆ្នាំ២០១៥:បូកសរុបលទ្ធផលការងារ ខែ សីហា និងកញ្ញា និងថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១៥ :បូកសរុបលទ្ធផលការងារ ខែ តុលា និងវិច្ឆិកា ។